

# គេមិនធ្វើបែបហ្នឹងទេ ម៉ីហុង!

Rachmad Ridduan

Ratna Kusuma Halim

Let's Read

The Asia Foundation



ម៉ីហុងចូលចិត្តមើលមិត្តភក្តិរបស់គេលេងប្រលែងគ្នា ។ ម៉ីហុង
ចង់ចូលលេងជាមួយពួកគេដែរ ប៉ុន្តែគ្មាននរណាចង់ឱ្យម៉ីហុង
ចូលរួមនោះទេ ។
ពួកគេតែងនិយាយថា " គេមិនធ្វើបែបនេះទេ ម៉ីហុង " ។



អ៊ូ! ថ្នាំពណ៌ទាំងនោះនឹងបង្កើតបានជាគំនូរដ៏ស្រស់ស្អាតមួយ។ ម៉ីហុងក៏ចង់គូរដែរ។ ប៉ុន្តែបន្ទាប់មក ក្ងានទាំងនោះបានស្រែកដាក់វា។ ”គេមិនមែនធ្វើបែបនេះទេ ម៉ីហុង”





សេះ បានអរគុណទៅកាន់ពពែឈ្មោះ ប៉ុក ដែលជួយយកអាសា។ សត្វដទៃទៀតក៏អរគុណវាដែរ។ ”ខ្ញុំក៏ចង់ជួយសត្វដទៃទៀតដូចពពែដែរ!”



ហ៊ឺ ... លោកយាយក្ដាន់ដូចជាកំពុងតែត្រូវការជំនួយ។ ម៉ីហុង
និយាយ "តោះលោកយាយ ចាំខ្ញុំជួយជូនលោកយាយឆ្លងផ្លូវ។"



ពួកយើងឆ្លងផ្លូវរួចហើយ ។
ម៉ីហុង មានមោទនភាពចំពោះខ្លួនឯងណាស់។
ប៉ុន្តែ ហេតុអ្វីបានជាលោកយាយបែរជាខឹងម៉ីហុងទៅវិញ?
វាមិនយល់សោះ។



មីហុង ប្រហែលជាសំណាងជាងមុនបើទៅជួយលោកពូចៀម
វិញ ។ "លោកពូ ចាំខ្ញុំជួយ!" មីហុង ធ្វើការយ៉ាងលឿន។



រួចរាល់ហើយ !
ម៉ីហុង ប្រាកដក្នុងចិត្តណាស់ថាលោកពូចៀមប្រាកដជា សប្បាយចិត្ត។
ប៉ុន្តែ ហេតុអ្វីបានជាលោកពូចៀមបែរជាខឹងទៅវិញ?
គាត់បាននិយាយថា "គេមិនធ្វើបែបនេះទេ ម៉ីហុង!"



មើលនោះ មួករបស់អ៊ំស្រីគោ ទើរលើមែកឈើហើយ។
ម៉ីហុងមកដល់ភ្លាមបាននិយាយថា ”ចាំខ្ញុំជួយយកវាឱ្យអ៊ំស្រី”



"ទេ ឈប់សិន!" អ៊ំស្រីគោបានស្រែក។
អូទេ! ហេតុអ្វីបានជាគាត់មិនសប្បាយចិត្តទៀតហើយ?



វីវរហើយ តើមីុហុងចុះមកវិញបានយ៉ាងម៉េចទៅ ?



"អរគុណ បងស្វា"

ឥឡូវនេះ មីហុងកាន់តែឆ្ងល់ហើយ។ ហេតុអ្វីបានជាមើលទៅគ្រប់គ្នាមិនសប្បាយចិត្តសោះ?

គ្រប់គ្នាបានស្រែកថា "គេមិនធ្វើបែបនេះទេ មីហុង"



លោកពូចៀមបានស្រែកប្រាប់ ”ឯងគួរតែសួរពូជាមុន។ ក្រញាំរបស់ឯងបានធ្វើឱ្យប៉េងប៉ោះខូចអស់ហើយ។”
លោកយាយក្ដាន់ បាននិយាយដោយខឹងថា ”យាយមិនបានចង់ឆ្លងផ្លូវទេ!”
អ៊ំស្រីគោក៏បាននិយាយដែរថា ”ម៉ីហុង អ៊ំយកម្ហូកទៅហាលទេតើ។”



អូ... ការពិតគឺ ម៉ីហុង យល់ច្រឡំសោះ។ សំណាងល្អ គ្រប់គ្នាបានអភ័យទោសឱ្យ ម៉ីហុង។ ពួកគេបាននិយាយថាវាជាការល្អដែល ម៉ីហុង ចង់ជួយអ្នកដទៃ។



មីុហុង បានយល់ហើយ។
គេគួរតែសួរមុនពេលដែលចង់ជួយអ្នកដទៃ។
”អ្នកមីងក្ងាន តើមានអ្វីឱ្យខ្ញុំជួយបានទេ ?



ឥឡូវនេះ ម៉ីហុង ដឹងថាគួរធ្វើបែបណាហើយ។

រក្សាសិទ្ធិដោយអង្គការមូលនិធិអាស៊ី ឆ្នាំ២០១៩

សៀវភៅនេះត្រូវបានបង្កើតឡើងតាមរយៈសិក្ខាសាលាអំពីការផលិតសៀវភៅជាភាសាជាតិដែលរួមសហការរវាង មូលនិធិ លីតារ៉ា អង្គការមូលនិធិអាស៊ី និង អាយអេសអាយ ប៉ាដាង ប៉ាន់ចាង នៅកោះស៊ូម៉ាត្រាខាងលិច។សិក្ខាសាលា និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ រួមទាំងការកែសម្រួលសៀវភៅនេះ គឺបានធ្វើឡើងដោយមូលនិធិ លីតារ៉ា។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Indak Takah Itu Caronyo Do, Mehung (That's Not How You Do It, Mehung)*, Author: Rachmad Ridduan. Illustrator: Ratna Kusuma Halim. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: Se Minea, Somey Chheang, bBunleang, and Chou Chinith